ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

លេខៈ ០៥ សព៧៩

# សេចក្ដីណែនាំ
## អនុវត្តខ្លឹមសារប្រកាសលេខ ១៥១ប្រក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១២ ស្ដីពីការគ្រប់គ្រងអាជីវកម្មសេវាថតចម្លង

ក្នុងទិសដៅពង្រឹងការអនុវត្តច្បាប់ស្ដីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងក្នុងគោលបំណងថែរក្សា ការពារ និងលើកតម្លៃអ្នកនិពន្ធប្រកបដោយភាពថ្លៃថ្នូរ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈសូមធ្វើការណែនាំដល់ថ្នាក់ដឹកនាំមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ និងអាជីវករសេវាថតចម្លងដូចខាងក្រោមៈ

**១- បែបបទសុំអនុញ្ញាតប្រកបអាជីវកម្ម**

អាជីវករទាំងអស់ ត្រូវបំពេញសំណុំបែបបទសុំការអនុញ្ញាត ប្រកបអាជីវកម្មសេវាថតចម្លងទៅតាមប្រភេទនៃសេវាកម្មនីមួយៗ ដូចមានចែងក្នុងប្រការ២ នៃប្រកាសលេខ១៥១ប្រក ចុះថ្ងៃ ទី០៥ ខែកក្កដា ឆ្នាំ២០១២ ស្ដីពីការគ្រប់គ្រងអាជីវកម្មសេវាថតចម្លងនៅមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានីខេត្ត។

សំណុំបែបបទរួមមានៈ

១-ពាក្យស្នើសុំ (មានបិទតែមប្រ៍).......................ចំនួន ០១សន្លឹក

២-កិច្ចសន្យា....................................................ចំនួន ០១សន្លឹក

៣-ប្លង់បង្ហាញទីតាំង..........................................ចំនួន ០១សន្លឹក

៤-អត្តសញ្ញាណប័ណ្ណ(ច្បាប់ចម្លង)....................ចំនួន ០១សន្លឹក

៥-រូបថត (៤×៦)................................................ចំនួន ០៣សន្លឹក

**២- ការអនុញ្ញាតនិងកម្រៃសេវាកម្ម**

រាល់ការអនុញ្ញាតត្រូវមានកម្រៃសេវាកម្ម ដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាង ក្រសួងវប្បធម៌និងវិចិត្រសិល្បៈនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬ តាមតារាងកម្រៃសេវាកម្ម វប្បធម៌និងវិចិត្រសិល្បៈរបស់ក្រុង ស្រុក ខណ្ឌ គោលដៅដែលបានទទួលការធ្វើប្រតិភូកម្មមុខងារ និងភារកិច្ចពីក្រសួងវប្បធម៌និងវិចិត្រ សិល្បៈ។

ការផ្ដល់សេចក្ដីអនុញ្ញាត ឬ មិនអនុញ្ញាតត្រូវកំណត់ក្នុងរយៈពេល៥ ( ប្រាំ ) ថ្ងៃ នៃថ្ងៃធ្វើការ ។ ប័ណ្ណអនុញ្ញាតមានសុពលភាពត្រឹមរយៈពេល១(មួយ) ឆ្នាំ ។ ការស្នើសុំបន្តអាជីវកម្មត្រូវអនុវត្តក្នុងរយៈពេល៣០ ( សាមសិប ) ថ្ងៃ មុនពេលផុតកំណត់ ។

**៣- លក្ខខណ្ឌអនុវត្ត**

ក្រោយទទួលបានសេចក្តីណែនាំនេះ ប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈគ្រប់រាជធានីខេត្ត ត្រូវ:

**ក**-សុំគោលការណ៍ទៅគណៈអភិបាលរាជធានី ខេត្ត រៀបចំផ្សព្វផ្សាយសេចក្តីណែនាំនេះ ឲ្យបានជ្រួតជ្រាបនៅតាមមន្ទីរ អង្គភាព សហគ្រាស និងទីតាំងអាជីវកម្ម សេវាកម្មទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**ខ**-ចុះស្រង់ស្ថិតិទីតាំងអាជីវកម្មសេវាថតចម្លងគ្រប់ប្រភេទ ដែលកំពុងធ្វើសកម្មភាពផ្តល់សេវាកម្ម និងត្រូវធ្វើចំណាត់ថ្នាក់ទីតាំងអាជីវកម្មទាំងនោះទៅតាមទំហំអាជីវកម្មជាក់ស្តែង។

**ខ.១**- សេវាថតចម្លងឯកសារត្រូវចែកជា២ ( ពីរ ) ប្រភេទគឺៈ

-សេវាកម្មប្រើប្រាស់ឧបករណ៍ម៉ាស៊ីនថតចម្លង៣គ្រឿងចុះ និង

-សេវាកម្មប្រើប្រាស់ឧបករណ៍ម៉ាស៊ីនថតចម្លង៤គ្រឿងឡើង។

**ខ.២**- សេវាថតចម្លងបោះពុម្ព លើក្រដាស សាច់សំពត់ ជ័រប្លាស្ទិក និងលោហៈត្រូវចែកជា ២ ( ពីរ )ប្រភេទគឺៈ

-សេវាថតចម្លងអូសស្បៃ

-សេវាថតចម្លងបោះពុម្ពដោយម៉ាស៊ីន។

**ខ.៣**- សេវាថតចម្លងបញ្ចូលបទចម្រៀង/ឬរូបភាពក្នុងទូរសព្ទដៃ

**គ**-សហការឲ្យបានជិតស្និទ្ធជាមួយនាយកដ្ឋានសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែលនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

**ឃ**-ផ្តល់របាយការណ៍ប្រចាំខែ ពីសកម្មភាពអាជីវកម្ម សេវាថតចម្លងមកនាយកដ្ឋានសិទ្ធិអ្នក-និពន្ធនិងសិទ្ធិប្រហាក់ប្រហែលដោយត្រូវរាយការណ៍ពីផលប៉ះពាល់ និងបាតុភាពអសកម្មផ្សេងៗដែលកើតឡើងពីការអនុវត្តនោះមកក្រសួង ដើម្បីជួយរិះរកមធ្យោបាយដោះស្រាយឲ្យបានទាន់ពេលវេលា។

ក្រសួងសង្ឃឹមនិងជឿជាក់យ៉ាងមុតមាំថា លោក លោកស្រីជាថ្នាក់ដឹកនាំមន្ទីរវប្បធម៌និង វិចិត្រសិល្បៈរាជធានី ខេត្តនិងអាជីវករទាំងអស់នឹងចូលរួមជួយសហការជំរុញកិច្ចការនេះឲ្យទទួលបានជោគជ័យ សំដៅលើកតម្កើងកិត្យានុភាពជាតិយើងឲ្យខ្ពង់ខ្ពស់ជាអារ្យប្រទេសមួយលើសកលលោក។

រាជធានីភ្នំពេញ ថ្ងៃទី១០....ខែសីហា..ឆ្នាំ២០១២

រដ្ឋមន្ត្រី

ហ៊ឹម ឆែម

កន្លែងទទួល

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួងស្ថាប័ន

-សាលារាជធានី ខេត្ត

-មន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត

- ឯកសារ កាលប្បវត្តិ